ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Jul-2011, 14:21
CMS/CFO: Uch Arun

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស ឬ អង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំពន្យារពេលឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម III, អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការដកលក្ខខណ្ឌតម្រូវ ស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ

| | |
|---|---|
| លោក ពេជ អង្គ | លោក Michiel PESTMAN |
| Elisabeth SIMONNEAU FORT | លោក Victor Koppe |
| | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅសៀង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

# សំណើ

១. ដោយអនុលោមតាមវិធាន ៣៩.៤ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញា ("កសព") សូមស្នើដោយគោរព សុំពន្យារពេល ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងចម្លើយតបរបស់មេធាវី ការពារក្តីដែលមិនទាន់បានតបទៅនឹង "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត"[1], "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[2] ហើយ "សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[3] ("សេចក្តីសន្និដ្ឋានរបស់កសព")។

២. នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ អ្នកសម្របសម្រួលជាន់ខ្ពស់របស់តុលាការ កញ្ញា Susan Lamb បានផ្តល់ប្រឹក្សាតាមរយៈអ៊ីមែលដល់ភាគីទាំងថា ចម្លើយតបទៅនឹងសេចក្តីសន្និដ្ឋានទាំងឡាយរបស់ កសព ត្រូវដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ហើយបានអនុញ្ញាតឱ្យ កសព នូវ រយៈពេលចំនួន១០ថ្ងៃ ដើម្បីធ្វើការឆ្លើយតបវិញ។ យោងទៅតាមក្របខ័ណ្ឌនៃពេលវេលានេះ ចម្លើយតបរបស់ កសព ត្រូវដាក់នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១។

៣. កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានទទួលនូវសេចក្តីជូនដំណឹងអំពីចម្លើយតបចំនួន៣របស់មេធាវីការពារក្តីដែលបានដាក់ជូនកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ដោយសហ

[1] **E100**, សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត, ថ្ងៃទី១៧ មិថុនា ២០១១, លេខERN 00708242-56 ។

[2] **E99**, សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទសារជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី១៦ មិថុនា ២០១១, លេខERN 00708301-15 ។

[3] **E95**, សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី១៥ មិថុនា ២០១១, លេខERN 00705887-901 ។

មេធាវីរបស់ អៀង ធីរិទ្ធ ដែលចម្លើយតបមួយត្រូវបានដាក់តែភាសាអង់គ្លេសមួយប៉ុណ្ណោះ[4]។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ខៀវ សំផន បានណែនាំដល់ការិយាល័យសហព្រះរាជអាជ្ញាថា ក្រុមខ្លួនបានដាក់ចម្លើយតបដោយឡែកទៅនឹងសារណាទាំង៣នោះរួចហើយកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលការជូនដំណឹងអំពីចម្លើយតប២ របស់មេធាវីការពារក្ដីមានតែភាសាអង់គ្លេសដែលបានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ដែលបានដាក់ដោយមេធាវីការពារក្ដី នួន ជា[5]។ ចម្លើយតបជាភាសាខ្មែរមិនទាន់បានដាក់ទេ។ រហូតមកទល់នឹងពេលនៃការដាក់សំណើនេះ មិនមានចម្លើយតបពីក្រុមមេធាវីការពារក្ដីរបស់ អៀង សារី ឬ ខៀវ សំផន ត្រូវបានជូនដំណឹងមកនៅឡើយទេ។

៤. នៅសល់ពេលចំនួនបួនថ្ងៃពេញមុននឹងដល់ថ្ងៃផុតកំណត់សម្រាប់ កសព ដាក់ការឆ្លើយតបគឺវាស្ថិតក្នុងរយៈពេលដែល កសព នៅមិនទាន់បានទទួលចម្លើយតបណាមួយពី អៀង សារី, ខៀវ សំផន និងនៅមិនទាន់បានទទួលចម្លើយតបចំនួនបីពី អៀង ធីរិទ្ធ និង នួន ជា ជាភាសាខ្មែរ រួមគ្នានៅឡើយទេ។ នៅក្នុងអម្លុងពេលនេះ ការបកប្រែឯកសារ គឺជាតម្រូវការចាំបាច់។ ដើម្បីជាប្រយោជន៍នៃប្រសិទ្ធភាព កសព មានបំណងដាក់ការឆ្លើយតបរួមមួយទៅនឹងចម្លើយតបរបស់មេធាវីការពារក្ដី, បន្ទាប់ពីបានទទួល, លើបញ្ហាជាសារធាតុចំនួនបី ដែលមានចរិតលក្ខណៈស្មុគស្មាញ និងលើកពីបញ្ហាទូទៅមួយចំនួន។ ដោយសារពុំមានការជូនដំណឹងនៅក្នុងករណីរបស់អៀង សារី និង ខៀវ

---

[4] ឯកសារលេខ E99/2 , ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ "សហព្រះរាជអាជ្ញា"ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់បទចោទជាថ្មីឡើងវិញលើអង្គហេតុដែលបង្ហាញភស្តុតាងអំពីការប្រព្រឹត្តបទរំលោភសេពសន្ថវៈ ដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងបទរំលោភសេពសន្ថវៈ ជាជាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងបទអំពើអមនុស្សធម៌ផ្សេងៗទៀត", ចុះថ្ងៃទី២២ កក្កដា ២០១១, ERN 00716118-32 ។ ឯកសារលេខ E100/1 ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ "សហព្រះរាជអាជ្ញា" ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា សហកម្មឧក្រិដ្ឋកម្មរួមគឺជាទម្រង់នៃការទទួលខុសត្រូវដែលជាជម្រើសសំរាប់ជំនួសមួយ", ចុះថ្ងៃទី២២ កក្កដា ២០១១, ERN 00714810-22។ ឯកសារលេខ E95/2, ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ "សហព្រះរាជអាជ្ញា" ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើវិសោធនកម្មលើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ", ចុះថ្ងៃទី២២ កក្កដា ២០១១ ERN 00714797-809។

[5] **E100/5** , ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ "សហព្រះរាជអាជ្ញា" សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកសហកម្មឧក្រិដ្ឋកម្មរួមទម្រង់ III ជាទម្រង់នៃការទទួលខុសត្រូវ ជាជម្រើសម្យ៉ាងទៀត, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00717650-7 ។ **E95/5**, ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ "សហព្រះរាជអាជ្ញា" សុំឱ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ថ្ងៃទី២២ កក្កដា ២០១១, លេខERN 00717406-14។

សំផន ហើយការជូនដំណឹងដែលបានពន្យារពេលក្នុងករណីរបស់ អៀង ធីរិទ្ធ និង នួន ជា ដែលមានចម្លើយតបចំនួនបីសុទ្ធតែជាភាសាអង់គ្លេសនោះ កសព នឹងមិនអាចត្រៀមរៀបចំ ព្រមទាំងធ្វើការបកប្រែនូវឯកសារចម្លើយតបមួយដែលមានសំអាងហេតុ ស្របទៅតាមពេលវេលាកំណត់បច្ចុប្បន្ននេះឡើយ។

៥. អាស្រ័យដូចមូលហេតុទាំងនេះ កសព សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យ កសព ដាក់ចម្លើយតបរបស់ខ្លួននៅក្នុងរយៈពេល១០ថ្ងៃ នៃថ្ងៃជូនដំណឹងចុងក្រោយបង្អស់នៃចម្លើយតបរបស់មេធាវីការពារទៅនឹងសេចក្តីសន្និដ្ឋានរបស់ កសព ជាភាសាអង់គ្លេស និងភាសាខ្មែរ។ គេសន្និដ្ឋានថា ការពន្យារពេលនេះនឹងបំពេញបានទៅតាមបំណងរបស់អង្គជំនុំជម្រះសាលាដំបូង គឺអនុញ្ញាតឱ្យអ្នកច្បាប់ដែលនិយាយភាសាខ្មែរនៅ កសព ធ្វើវិភាគទាននៅក្នុងការវាយតម្លៃការព្រាង និងការពិនិត្យឡើងវិញ ព្រមទាំងអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាផ្តល់ជូននូវសេចក្តីសន្និដ្ឋានមួយដែលខ្លីហើយច្បាស់លាស់ និងធានាបានចំពោះការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវធនធាននៃការបកប្រែរបស់ អ.វ.ត.ក៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |